ទីស្តីការក្រសួងយុត្តិធម៌
លេខ ០៤ សរច-៩៤

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ
## <u>សារាចរ</u>
## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌
## <u>ផ្ញើចំពោះ</u>

លោកប្រធាតុលាការ គ្រប់ខេត្ត ក្រុង
លោកព្រះរាជអាជ្ញាអមតុលាការគ្រប់ខេត្ត ក្រុង

<u>សូមជ្រាប។</u>

**<u>កម្មវត្ថុ:</u>** ការណែនាំអំពីនីតិវិធីប្តឹងទាស់ និងបណ្តឹងឧទ្ធរណ៍របស់គូក្តី ចំពោះសលាក្រមតុលាការខេត្ត ក្រុង ។
**<u>យោង:</u>** មាត្រា ៧ និង៨ នៃច្បាប់ស្តីពីការចាត់តាំងនិងសម្មភាពរបស់សាលាជម្រះក្តី និងមាត្រា១១១,១១២,១១៦, ១១៧,១១៨,១១៩,១២០,១៧៦,១៧៧,និង១៧៨ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ។

កន្លងមកក្រសួងបានសង្កេតឃើញថា តុលាការខ្លះនៅមានការខ្វះខាតក្នុងការអនុវត្តទីបទបញ្ញាត្តិស្តីពីការប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ ។ ដើម្បីបញ្ចប់ការខ្វះខាតនេះ ក្រសួងសុំរំលឹកដូចតទៅ ៖

ក-អំពីដីកាកោះ ឬសេចក្តីជូនដំណឹងពីសេចក្តីសម្រេចផ្សេងៗរបស់តុលាការ ៖ បញ្ហានេះតុលាការត្រូវយកចិត្តទុកដាក់ ចាត់វិធានការផ្តល់ដំណឹងដល់គូក្តីអោយបានត្រឹមត្រូវតាមច្បាប់កំណត់ រួចយកលិខិតដើមមកដាក់ក្នុងសំណុំរឿងវិញ ។

ខ-អំពីការជូនដំណឹងពីសាលក្រមកំបាំងមុខដល់គូក្តី ដែលមិនបានចូលខ្លួនមកចំពោះមុខតុលាការត្រូវធ្វើយ៉ាងណាជូនដំណឹងនោះអោយបានដល់គូក្តី ហើយប្រាប់គូប្តីអោយយល់ពីសិទ្ធិរបស់គេ ដើម្បីអោយអាចចូលមកប្តឹងតវ៉ាទាន់ពេលវេលា ។

គ-អំពីការប្រកាសសាលក្រមចំពោះមុខគូក្តី ត្រូវប្រកាសថាសាលក្រមនេះប្រកាសជាសាធារណៈចំពោះមុខគូភាគី បើកផ្លូវឧទ្ធរណ៍កំណត់២ខែ គិតពីថ្ងៃនេះតទៅរួចត្រូវណែនាំបន្ថែមអោយបានច្បាស់ថាបើភាគីណាមិនសុខចិត្តពីសេចក្តីសម្រេចទេត្រូវផ្តិតមេដៃ ឬចុះហត្ថលេខា ប្តឹងឧទ្ធរណ៍ពីសេចក្តីសម្រេចនេះនៅការិយាល័យក្រឡាបញ្ជីនៃតុលាការនេះក្នុងរយៈពេល២ខែ គិតពីថ្ងៃសម្រេចសេចក្តីនេះតទៅ ។

នៅពេលដែលគូក្តីចូលមកប្តឹងឧទ្ធរណ៍ពីសាលក្រមណាមួយរបស់តុលាការ អ្នកទទួលបណ្តឹងត្រូវសួរបញ្ជាក់ដល់អ្នកប្តឹងថាតើគេប្តឹងមិនសុខចិត្តនឹងសាលក្រមទាំងមូល ឬមិនសុខចិត្តពីចំណុចណាមួយនៃសាលក្រមនោះ ក្រសួងតម្រូវអោយចៅក្រមជំនុំជម្រះពន្យល់ដល់គូក្តី ពិសេសអ្នកចាញ់ក្តីអោយបានយល់ច្បាស់លាស់រំពីសិទ្ធិប្តឹងឧទ្ធរណ៍នេះ កុំអោយអ្នកចាញ់ក្តីនោះភាន់ច្រឡំ ឬស្តាប់មិនបាន ។

ឃ-អំពីការប្តឹងឧទ្ធរណ៍ ឬប្តឹងទាស់ពីសាលក្រមរបស់តុលាការខេត្ត-ក្រុង ដោយគូក្តីណាមួយមិនត្រូវតម្រូវជាចាំបាច់អោយគូក្តីនោះធ្វើពាក្យប្តឹងទាស់ ឬ ឧទ្ធរណ៍ទេគឺគ្រាន់តែអោយធ្វើក្តីនោះផ្តិតមេដៃ ឬ ចុះហត្ថលេខាលើសៀវភៅបណ្តឹងតវ៉ានិងចុះថ្ងៃ ខែ ឆ្នាំ អោយបានច្បាស់លាស់តែប៉ុណ្ណោះ អាចចាត់ទុកជាបានការគ្រប់គ្រាន់តាមផ្លូវច្បាប់ហើយ ។ ប្រសិនបើអ្នកប្តឹងចង់បានសេចក្តីបញ្ជាក់ពីបណ្តឹងឧទ្ធរណ៍ ឬបណ្តឹងទាស់នោះក្រឡាបញ្ជីត្រូវចេញសេចក្តីបញ្ជាក់អោយភ្លាម ។ ចំណែកសេចក្តីដែលមានចុះនៅបន្ទាត់ចុងបំផុតនៃសន្លឹកបណ្តឹងក្នុងសៀវភៅបណ្តឹងតវ៉ា

ដែលថាអ្នកប្តឹងទាស់ ឬ ប្តឹងឧទ្ធរណ៍ ត្រូវធ្វើពាក្យជូនតុលាការឱ្យបានទាន់ពេលវេលា នោះពុំមានន័យថាត្រូវអោយអ្នកប្តឹងនោះធ្វើពាក្យជាមុនទើបអាចទទួលចុះបណ្តឹងទាស់ ឬ បណ្តឹងឧទ្ធរណ៍អោយទេ ។ ត្រង់នេះមានន័យថា អ្នកប្តឹងតវ៉ាត្រូវធ្វើពាក្យបង្ហាញហេតុផល និងជូនភស្តុតាង ពីបណ្តឹងរបស់ខ្លួនជូនតុលាការខេត្ត-ក្រុង ដែលទទួលបណ្តឹងទាស់ ឬ ជូនទៅសាលាឧទ្ធរណ៍អោយបានមុនពេលតុលាការបើកសវនាការ ធ្វើការពិភាក្សាដេញដោលពិនិត្យលើបណ្តឹងទាស់ ឬ បណ្តឹងឧទ្ធរណ៍ដល់អង្គសេចក្តីតែប៉ុណ្ណោះ ។

ង-ចំពោះបណ្តឹងទាស់ តាមគោលការណ៍គូក្តីត្រូវប្តឹងនៅការិយាល័យក្រឡាបញ្ជីនៃតុលាការ ប៉ុន្តែគេអាចប្តឹងបានដែរតាមសំបុត្រអនុសិដ្ឋ ឬសំបុត្រធម្មតា ឬតាមបណ្តឹងធ្វើនៅចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌ ក្នុងករណីនេះថ្ងៃ ខែ ឆ្នាំ ដែលប្តឹងតវ៉ាគឺកំណត់យកថ្ងៃ ខែ ឆ្នាំ ដែលត្រូវប្រៃសណីយ៍ ឬការិយាល័យនគរបាលយុត្តិធម៌បានចុះក្នុងបញ្ជីចូលទៅកន្លែងអង្គការនោះទុកជាថ្ងៃ ខែ ឆ្នាំ ដែលគូក្តីបានចូលទៅតវ៉ាក្នុងកំណត់ច្បាប់ ។

ច-ចំពោះបណ្តឹងឧទ្ធរណ៍វិញ គេត្រូវតែចូលទៅប្តឹងនៅការិយាល័យក្រឡាបញ្ជីនៃតុលាការសាមីតាមរយៈពេលដែលច្បាប់បានកំណត់ ។ ថ្ងៃ ខែ ដែលកំណត់យកជាការនោះ គឺថ្ងៃ ដែលអ្នកប្តឹង ចុះហត្ថលេខា ឬផ្តិតមេដៃលើបណ្តឹងដែលចុះក្នុងបញ្ជី ។

ឆ-នៅមុខសាលាជំនុំជម្រះក្តីនៃតុលាការខេត្ត-ក្រុង នីមួយៗលោកប្រធានតុលាការ ត្រូវធ្វើផ្លាកដាក់ពីមុខដោយសរសេរថា ៖

<u>**សេចក្តីជូនដំណឹង**</u>

អំពីសិទ្ធិប្តឹងទាស់ ពីសាលក្រមកំបាំងមុខ និងសិទ្ធិប្តឹងឧទ្ធរណ៍ពីសាលក្រមចំពោះមុខ៖

១-សាលក្រមកំបាំងមុខលើកទី១ គូក្តីណាមិនសុខចិត្តអាចប្តឹងជំទាស់ក្នុងរយៈពេល១៥ថ្ងៃ គិតពីថ្ងៃទទួលដំណឹងពីសេចក្តីសម្រេចរបស់តុលាការ ។

២-សាលក្រមកំបាំងមុខលើកទី២ ទុកដូចជាចំពោះមុខគូក្តី ។ គូភាគីអាចប្តឹងឧទ្ធរណ៍ក្នុងរយៈពេល២ខែ គិតពីថ្ងៃអោយដំណឹង ។

៣-សាលក្រមចំពោះមុខគូក្តី គូប្តីអាចប្តឹងឧទ្ធរណ៍បានក្នុងរយៈពេល២ខែ គិតពីថ្ងៃសម្រេចសេចក្តីរបស់តុលាការតទៅ ។

៤-ការប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ភាគីណាមិនសុខចិត្តត្រូវចូលទៅប្តឹងតវ៉ានៅការិយាយ័យក្រឡាបញ្ជីនៃតុលាការនោះ តាមរយៈពេលដូចបានកំណត់ជូនខាងលើ ។

ជ-ជាចាំបាច់ ក្រឡាបញ្ជីត្រូវចេញលិខិតបញ្ជាពីករណីនីមួយៗខាងលើនេះ ជូនគូក្តីដើម្បីឲ្យគេយល់ច្បាស់អំពីសិទ្ធិរបស់គេ ។

ឈ-ពេលតទៅ អ្នកប្រព្រឹត្តមិនសមស្រប ក្រសួងនឹងតម្រូវអោយទទួលខុសត្រូវជាវិន័យរដ្ឋបាល ដោយមិនទាន់គិតដល់ការខូចខាតប្រសិនបើមាន ។

ញ-ក្រោយពីបានទទួលសារាចរនេះ លោកប្រធានតុលាការខេត្ត-ក្រុង នីមួយៗត្រូវប្រជុំបុគ្គលិកទាំងអស់នៃតុលាការរៀងៗខ្លួន ហើយផ្សព្វផ្សាយអោយយល់ច្បាស់អំពីខ្លឹមសារនៃសារាចរនេះ រួចធ្វើរបាយការណ៍ត្រឡប់ទៅក្រសួងវិញជាបន្ទាន់ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី២២ ខែមីនា ឆ្នាំ១៩៩៤

**រដ្ឋមន្ត្រី**

**ចែម សួន**

<u>ចម្លងជូន</u>

-តុលាការកំពូល

-តុលាការសាលាឧទ្ធរណ៍

-អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល

-អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍